Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយភ្លាមៗ

# មេគង្គបន្តរីកចម្រើន ប៉ុន្តែនៅជួបបញ្ហាប្រឈមខ្លាំងៈ របាយការណ៍ថ្មីរបស់គណៈកម្មការទន្លេមេគង្គ

**ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០២៣** — គណៈកម្មការទន្លេមេគង្គ ដែលហៅកាត់ថា MRC បានចេញផ្សាយ របាយការណ៍ប្រចាំឆ្នាំ២០២២ របស់ខ្លួនដែលកត់ត្រានូវសមិទ្ធិផល ជាច្រើនក្នុងរយៈពេលមួយឆ្នាំកន្លងមក ក៏ដូចជាបញ្ហាប្រឈមសំខាន់ៗដែលអាងទន្លេកំពុងជួបប្រទះដែលទាមទារការយកចិត្តទុកដាក់ជាពិសេស។

របាយការណ៍ប្រចាំឆ្នាំ ២០២២ របស់ គណៈកម្មការទន្លេមេគង្គ កត់ត្រាការរីកចម្រើនជាក់ស្តែងទូទាំង អាងទន្លេមេគង្គ ដែលសម្រេចបានតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នា និង "ការទូតទឹក" នៃប្រទេសជាសមាជិកដែលរួមមាន៖ កម្ពុជា ឡាវ ថៃ និងវៀតណាម និងដៃគូនានា។

ក្នុងចំណោមសមិទ្ធិផលសំខាន់ៗជាច្រើនកាលពីឆ្នាំមុន មានដូចជា៖ គោលការណ៍ណែនាំថ្មីសម្រាប់ការរៀបចំទំនប់វារីអគ្គីសនីនៅលើទន្លេមេ និងផលប៉ះពាល់បរិស្ថានឆ្លងដែនដើម្បីសម្រួលដល់ចលនាបំលាស់ទីរបស់ត្រី និងលំហូរដីល្បាប់, បែបបទនាវាចរណ៍ថ្មីដើម្បីលើកកម្ពស់សុវត្ថិភាពទន្លេឱ្យបានល្អជាងមុន, ឧបករណ៍ដែលមានភាពច្នៃប្រឌិត ដើម្បីព្យាករណ៍ទឹកជំនន់និងគ្រោះរាំងស្ងួតឱ្យបានប្រសើរជាងមុន, ស្ថានីយ៍ត្រួតពិនិត្យថ្មីនៅផ្នែកចុងខាងជើងនៃអាង ដើម្បីឱ្យដឹងពីការផ្លាស់ប្តូររបស់ទឹកឱ្យបានឆាប់រហ័ស, និងការចាប់ផ្តើមនៃការសិក្សារួមគ្នា (ជាមួយនឹងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង) ដើម្បីបង្កើតការយល់ដឹងរួមគ្នាទាំង ផ្នែកខាងលើ និងផ្នែកខាងក្រោម អំពីការផ្លាស់ប្តូរបែបលំហូរទឹក ដែលត្រូវបានគេមើលឃើញថា ជាតម្រូវការដំបូងដើម្បីកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពជាងមុន។

គណៈកម្មការទន្លេមេគង្គបានចាប់ផ្តើមអនុវត្តគោលការណ៍ណែនាំស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានឆ្លងដែន ឬ TbEIA ស្របពេលដែលការសិក្សារួមគ្នាបានបញ្ចប់ដំណាក់កាលដំបូងរបស់ខ្លួន។ លទ្ធផលនៃសិក្សាស្រាវជ្រាវនេះនឹងត្រូវបានចែករំលែកនៅក្នុង វេទិកាភាគីពាក់ព័ន្ធថ្នាក់តំបន់លើកទី១៣ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ នៅទីក្រុងលួងប្រាបាង ប្រទេសឡាវ។

លើសពីនេះទៅទៀត ដោយសារតែគណៈកម្មការទន្លេមេគង្គចង់បំពេញបន្ថែមទៅលើយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេឆ្នាំ២០២១-២០៣០ និងផែនការយុទ្ធសាស្ត្រឆ្នាំ២០២១-២០២៥ របាយការណ៍ប្រចាំឆ្នាំនេះពណ៌នាអំពីរបៀបដែលជាអាទិភាពជាយុទ្ធសាស្ត្រទាំងប្រាំរបស់ស្ថាប័នខ្លួន (រួមមាន៖ បរិស្ថាន សង្គម

សេដ្ឋកិច្ច ការប្រែប្រួលអាកាសធាតុ និងកិច្ចសហប្រតិបត្តិការ) មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់មនុស្ស សត្វ និងរុក្ខជាតិដែលរស់នៅតាមដងទន្លេមេគង្គរាប់លានប៉ុណ្ណោះទេ ថែមទាំង រួមចំណែកដល់ការសម្រេចបាននូវគោលដៅទាំង ១០ ក្នុងចំណោម "គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព" ទាំង១៧របស់សហគមន៍អន្តរជាតិ។

ថ្វីត្បិតមានព័ត៌មានល្អនៅថ្ងៃនេះក៏ដោយ (ដែលបច្ចុប្បន្នរួមមាន៖ កម្រិតទឹកភ្លៀងមានសភាពខ្ពស់ជាងឆ្នាំ ២០២១ និង ២០២២ ចំនួន ៤០% គុណភាពទឹកតាមដងទន្លេមេគង្គនៅតែមានសភាព "ល្អ" ឬ "ល្អឥតខ្ចោះ"នៅតំបន់ភាគច្រើន និងកំណើនដ៏ល្អប្រសើរនៃសេដ្ឋកិច្ច-សង្គមនិងស្តង់ដារស់នៅទូទាំងតំបន់) អាងទន្លេក៏នៅតែបន្តប្រឈមមុខនឹងបញ្ហាប្រឈមធំៗនានា។ ជាការពិត ក្នុងសុន្ទរកថារបស់បណ្ឌិត អានុល័ក គិធិឃួន នាយកប្រតិបត្តិនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គស្តីពីស្ថានភាពទន្លេមេគង្គកាលពីខែមេសាកន្លងទៅនេះ បានលើកឡើងពីនិន្នាការ "ដ៏គួរឱ្យព្រួយបារម្ភ" ចំនួនប្រាំដែលរួមមាន៖ បម្រែបម្រួលលំហូរទឹក កំណកកករ ការជ្រាបចូល ទឹកប្រៃឬទឹកសមុទ្រ ការបំពុលដោយបាស្ទីក និងទឹកជំនន់និងគ្រោះរាំងស្ងួតដែលមានស្ថានភាពកាន់តែធ្ងន់ធ្ងរដោយបម្រែបម្រួលអាកាសធាតុ។

ដូចដែលលោក គិធិឃួន បានបញ្ជាក់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំនេះ បញ្ហាប្រឈមទាំងនេះគឺមានចរិតលក្ខណៈឆ្លងដែន ដូច្នេះទាមទារឱ្យមានកិច្ចសហប្រតិបត្តិការជាបន្តរវាងប្រទេសតាមដងទន្លេដើម្បីដោះស្រាយ។ កិច្ចសហប្រតិបត្តិការនេះរួមបញ្ចូលទាំងតម្រូវការនៃការចែករំលែកទិន្នន័យ ការចរចាការសម្របសម្រួល និងការចូលរួមបន្ថែមទៀតសម្រាប់ដៃគូថ្នាក់តំបន់និងថ្នាក់អន្តរជាតិ។

លោក គិធិឃួន សរសេរក្នុងបុព្វកថា "យើងមានទន្លេមេគង្គតែមួយគត់" ។ "ដូច្នេះហើយ ជាការល្អបំផុតយើងគួរតែប្រកាន់យកនូវវិធីសាស្ត្រទូទាំងអាងទន្លេ សម្រាប់ការស្វែងរកដំណោះស្រាយ និងការសម្រេចចិត្តចំពោះអ្វីៗគ្រប់យ៉ាងចាប់ពីការរៀបចំប្លង់ទំនប់វារីអគ្គិសនី និងការតាមដានទន្លេរហូតដល់បែបបទនាវាចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធជាពសាស្ត្រ។

គណៈកម្មការទន្លេមេគង្គ គឺជាទីភ្នាក់ងារអន្តររដ្ឋាភិបាលតែមួយគត់ដែលត្រូវបានផ្តល់សេចក្តីទុកចិត្តឱ្យដោយសន្ធិសញ្ញា (កិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥) ដើម្បីការពារទន្លេ ធានាដល់ការប្រើប្រាស់ធនធានទឹករបស់ទន្លេប្រកបដោយសមធម៌ និងបង្កើនការអភិវឌ្ឍន៍សេដ្ឋកិច្ចជាអតិបរមា ស្របពេលដែលមានការកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន ឬសហគមន៍តាមដងទន្លេ (រួមមាន៖ គ្រួសារអ្នកនេសាទ និងកសិកររាប់លាននាក់ដែលពឹងផ្អែកលើទន្លេនេះសម្រាប់អាហារ និងការចិញ្ចឹមជីវិត)។

ស្របពេលដែលភាពខុសគ្នានឹងកើតឡើងម្តងម្កាលរវាងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ជាតិ និងអ្វីដែលល្អបំផុតសម្រាប់តំបន់ សមិទ្ធិផលដែលបានរៀបរាប់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំនេះបង្ហាញថា កិច្ចសហ

ប្រតិបត្តិការនៅទីបំផុតផ្តល់លទ្ធផលជាច្រើន ហើយនឹងបន្តផ្តល់លទ្ធផលបែបនេះនៅពេលអនាគតទៀត នេះបើយោងតាមមន្ត្រីជាន់ខ្ពស់ជនជាតិថៃម្នាក់ដែលបានលើកឡើងក្នុងរបាយការណ៍នេះ។

លោកបណ្ឌិត ស៊ូរ៉ាស្រី គិដជីមនធុន (Surasri Kidtimonton) សមាជិកនៃគណៈកម្មាធិការរួម នៃគណៈកម្មការទន្លេមេគង្គ សម្រាប់ប្រទេសថៃ ដែលជាអគ្គលេខាធិការនៃការិយាល័យធនធានទឹកប្រទេសថៃ និងលេខាធិការដ្ឋានគណៈកម្មាធិការទន្លេមេគង្គជាតិថៃផងដែរ មានប្រសាសន៍ថា "បច្ចុប្បន្ននេះ គណៈកម្មការទន្លេមេគង្គ មានគោលនយោបាយ និងនីតិវិធីរឹងមាំក្នុងការដោះស្រាយអភិបាលកិច្ចទឹកឆ្លងដែន ដោយផ្អែកលើគោលការណ៍សហប្រតិបត្តិការ កាតព្វកិច្ច និងសុច្ឆន្ទៈនៃសន្ធិសញ្ញា"។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**
គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីអភិវឌ្ឍន៍តំបន់នេះប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
លោក មាស សុភក្រ្ត មន្ត្រីជំនាញផ្នែកភាគីពាក់ព័ន្ធ
មន្ត្រីសារព័ត៌មានបណ្តោះអាសន្ន
លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរស័ព្ទដៃ៖ +៨៥៦-២០-៧៧៧៧៩១៦៨

###